**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

JS LAND PLC

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**
លេខ ២០២៤/០០៥/[illegible] ជ.អ.ល.

# សេចក្តីប្រកាស

## ស្តីពី

## ការមិនបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ ២០២៣ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ("ជ.អ.ល.")** សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក និងសាធារណជនទាំងអស់មេត្តាជ្រាបថា ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី បានពិចារណា និងសម្រេចមិនបែងចែកភាគលាភសម្រាប់ឆ្នាំ២០២៣ ជូនភាគហ៊ុនិករបស់ខ្លួននោះទេ ដោយសារតែសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនយើងខ្ញុំបានយល់ដឹងពីតម្រូវការចាំបាច់ក្នុងការបម្រុងទុកគ្រប់គ្រងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន ដោយធ្វើការប្រយ័ត្នក្នុងការតម្រឹមធនធានឆ្ពោះទៅរកការជំរុញកំណើន និងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍នាពេលអនាគតរបស់ក្រុមហ៊ុនផងដែរ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី មានសាច់ប្រាក់ និងសាច់ប្រាក់សមមូល ៨៥២.៨០៩.០០០ រៀល។ បន្ទាប់ពីឆ្លងកាត់ការវាយតម្លៃដោយល្អិតល្អន់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនយើងខ្ញុំ បានបង្ហាញយ៉ាងជាក់ស្តែងថា លំហូរសាច់ប្រាក់របស់ក្រុមហ៊ុនយើងខ្ញុំរឹតតែមានភាពតានតឹងជាងការរំពឹងទុក។ ក្រុមហ៊ុនយើងខ្ញុំ ចង់បន្តគ្រប់គ្រងសាច់ប្រាក់សម្រាប់គម្រោង The Garden Residency 3 (TGR3) និងសម្រាប់គម្រោងអភិវឌ្ឍនាពេលមុខដែលមានចំនួន ៥១.៣១៩.០២៩.៨៣០ រៀល។

យោងតាមគោលនយោបាយភាគលាភ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី នៃប្រយោគ "**លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការទូទាត់ភាគលាភ ឬធ្វើការបែងចែកផ្សេងៗទៅកាន់ភាគហ៊ុនិក គឺផ្អែកលើកត្តាពាក់ព័ន្ធផ្សេងៗ ដែលមានដូចជា ប្រាក់ចំណេញ និងសាច់ប្រាក់លើសដែលមិនត្រូវការសម្រាប់ផ្គត់ផ្គង់ធុរកិច្ចរបស់ក្រុមហ៊ុន។**" និងដោយស្របតាមលក្ខន្តិកៈ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ក្នុងជំពូក ៥ (ប្រាក់ចំណេញ ភាគលាភ និងទុនបម្រុង); ប្រយោគ ៤០ (ទុនបម្រុង)៖ "**អភិបាលមានសិទ្ធិក្នុងការកាត់ទុកនូវប្រាក់មួយផ្នែកនៃប្រាក់ចំណេញសុទ្ធ តាមការសមស្របសម្រាប់ផ្ទេរទៅក្នុងទុនបម្រុង ដើម្បីទុកប្រើប្រាស់ក្នុងការដំណើរការអាជីវកម្ម**"។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិក និងសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០២៤
**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី JS LAND PLC. KINGDOM OF CAMBODIA

ចុះបញ្ជីក្រោមលេខ
Registration No. 00010332

លេខ B២-១០៧ អគារ The Elysee កោះពេជ្រ វិថីកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#B2-107, The Elysee Diamond Island, Koh Pich Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 010 88 66 99
E-mail: info@jslandplc.com, Website: www.jslandplc.com